ការពិនិត្យឡើងវិញពីអព្យាក្រឹតភាពនៃការប្រកួតប្រជែងដោយ
អង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍសេដ្ឋកិច្ច (OECD)

# សេវាកម្មដឹកជញ្ជូនកញ្ចប់តូចនៅក្នុងប្រទេសកម្ពុជា

## ចំណុចសំខាន់ៗ

អព្យាក្រឹតភាពក្នុងការប្រកួតប្រជែង (អាជីវកម្មដែលជាកម្មសិទ្ធរបស់រដ្ឋ និងអាជីវកម្មឯកជនដែលការប្រកួតប្រជែងក្នុងទីផ្សារនៅកម្រិតស្មើគ្នា) ធានាថារាល់សហគ្រាសទាំងអស់ ទោះជាសាធារណៈឯកជនក្តី ជាសហគ្រាសក្នុងស្រុក ឬបរទេសក្តីប្រឈមចំពោះមុខច្បាប់តែមួយ។ ការធានាឱ្យបាននូវការប្រកួតប្រជែងស្មើភាពគ្នារវាងក្រុមហ៊ុនឯកជន និងក្រុមហ៊ុនសាធារណៈនៅក្នុងទីផ្សារនឹងនាំឱ្យមានជម្រើសកាន់តែច្រើន គុណភាពកាន់តែខ្ពស់ និងតម្លៃកាន់តែទាបសម្រាប់អ្នកប្រើប្រាស់នឹងផ្តល់ជាអត្ថប្រយោជន៍ដល់កំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍ។ នេះជាហេតុផលដែលថា ការវាយតម្លៃលើផលប៉ះពាល់របស់សហគ្រាសដែលជាកម្មសិទ្ធរបស់រដ្ឋ (SOEs) នៅក្នុងការប្រកួតប្រជែងជាកត្តា ដ៏មានសារៈប្រយោជន៍។

អង្គការ OECD ទទួលបានភារកិច្ចពីលេខាធិការដ្ឋានអាស៊ាន និងក្រុមអ្នកជំនាញអាស៊ានលើផ្នែកការប្រកួតប្រជែងក្រោមការឧបត្ថម្ភមូលនិធីពីកម្មវិធីកំណែទម្រង់សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Reform Programme) ក្រោមការិយាល័យអភិវឌ្ឍ ខូមិនវែល និងការបរទេសនៃចក្រភពអង់គ្លេស (UK Foreign, Commonwealth & Development Office) (រដ្ឋាភិបាលចក្រភពអង់គ្លេស) ដើម្បីធ្វើការវាយតម្លៃដោយឯករាជ្យទៅលើផលប៉ះពាល់នៃសហគ្រាសប្រភេទ SOEs ទៅលើការប្រកួតប្រជែងក្នុងវិស័យសេវាកម្មដឹកជញ្ជូនកញ្ចប់តូចក្នុងតំបន់អាស៊ាន។ លទ្ធផលនៃការវាយតម្លៃអាចជួយដល់ការលើកកម្ពស់ ការប្រកួតប្រជែងស្មើភាពគ្នារវាងសហគ្រាស SOEs និងស្ថាប័នឯកជនក្នុងតំបន់អាស៊ាន ជួយរកឱ្យឃើញសិទ្ធនឹងបុព្វសិទ្ធពិសេសនានា ដែលសហគ្រាស SOEs ទទួលបាន ដែលប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច និងការប្រកួតប្រជែងក្នុងរយៈពេលវែង។ ឯកសារនេះ បង្ហាញឱ្យឃើញលទ្ធផលចម្បងៗ ដែលបានមកពីការវាយតម្លៃ និងការពិនិត្យឡើងវិញ យ៉ាងពេញលេញដែលអាចរកបាននៅ oe.cd/comp-asean ។

ការត្រួតពិនិត្យឡើងវិញគឺជា លទ្ធផលនៃការវាយតម្លៃរបស់អង្គការ OECD ដោយផ្អែកលើការវិភាគទៅលើច្បាប់កម្ពុជាដែលត្រូវបានជ្រើសរើស (ជាអាទិភាព) ការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធ និងការសិក្សាស្រាវជ្រាវពីឯកសារនានា។ ការត្រួតពិនិត្យនេះត្រូវបានធ្វើឡើងជា ៤ ដំណាក់កាល៖

<u>**ដំណាក់កាលទី១**</u>គឺជាការកំណត់វិសាលភាពជាក់លាក់នៃការសិក្សា។ប្រែសណីយ៍កម្ពុជាត្រូវបានកំណត់ថាជាសហគ្រាសប្រភេទ SOE ដែលពាក់ព័ន្ធនឹងគោលបំណងនៃការសិក្សានេះ ហើយច្បាប់និងបទប្បញ្ញត្តិចម្បងៗ ព័ត៌មានពាក់ព័ន្ធនឹង SOE មួយចំនួនក៏ត្រូវបានធ្វើការវិភាគផងដែរ។ ក្រុមការងាររបស់អង្គការ OECD បានជួបជាមួយអាជ្ញាធររដ្ឋាភិបាល សមាគមឧស្សាហកម្ម និងភាគីឯកជនដែលពាក់ព័ន្ធ។

<u>**ដំណាក់កាលទី២**</u> បានត្រួតពិនិត្យទៅលើច្បាប់ដែលពាក់ព័ន្ធដើម្បីកំណត់ឱ្យឃើញមាត្រាជាសក្តានុពលដែលបង្កឱ្យមានផលប៉ះពាល់ដល់ទីផ្សារប្រកួតប្រជែងស្មើភាពគ្នា និងដើម្បីស្វែងយល់អំពីហេតុផល និងគោលបំណងនៃគោលនយោបាយរបស់ច្បាប់ទាំងនោះ។

**ដំណាក់កាលទី៣** គឺជាការវិភាគទៅលើសិទ្ធិពិសេស បុព្វសិទ្ធិ និងតួនាទីរបស់ប្រៃសណីយ៍កម្ពុជាយ៉ាងស៊ីជម្រៅ។
**ដំណាក់កាលទី៤** គឺជាដំណាក់កាលនៃការចងក្រងពង្រាងរបាយការណ៍មួយដែលរួមមានអនុសាសន៍ដែលមិនមែនជាកាតព្វកិច្ច។ សេចក្តីព្រាងការត្រួតពិនិត្យ និងអនុសាសន៍នានា ត្រូវបានចែករំលែកនិងលើកយកមកពិភាក្សាជាមួយភាគីពាក់ព័ន្ធក្នុងវិស័យសាធារណៈ។

## សហគ្រាសប្រភេទ SOE និងអព្យាក្រឹត្យភាពនៃការប្រកួតប្រជែង

សហគ្រាសប្រភេទ SOE អាចមានសិទ្ធ ឬបុព្វសិទ្ធដែលគូប្រកួតប្រជែងក្នុងវិស័យឯកជនមិនមាន ហើយសិទ្ធទាំងនេះ អាចផ្តល់ជាអត្ថប្រយោជន៍លើសលប់ក្នុង ការប្រកួតប្រជែង។ គុណប្រយោជន៍ទាំងនេះអាចធ្វើឱ្យការចូលទៅក្នុងទីផ្សារ ឬការពង្រីកទីផ្សារកាន់តែមាន ការលំបាកសម្រាប់ក្រុមហ៊ុនឯកជន (ទាំងក្នុងស្រុកនិងក្រៅស្រុក) និងនាំឱ្យមានឧបសគ្គក្នុងការប្រកួតប្រជែង។ ស្របពេលជាមួយគ្នានេះ សហគ្រាស SOE អាចនឹងទទួលកាតព្វកិច្ចដែលបង្កផលប៉ះពាល់ដល់សមត្ថភាពរបស់ខ្លួនក្នុងការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពជាមួយក្រុមហ៊ុនឯកជន។ ឧទាហរណ៍គុណសម្បត្តិនៃសហគ្រាស SOE ឬកត្តាដែលអាចប៉ះពាល់ដល់អព្យាក្រឹតភាពនៃការប្រកួតប្រជែងគឺ៖

| | | |
|---|---|---|
| ១ | ការប្រព្រឹត្តផ្នែកហិរញ្ញវត្ថុ → | ឧបត្ថម្ភធនទាំងស្រុង<br>ហិរញ្ញប្បទាននិងការធានារបស់រដ្ឋ |
| ២ | បទប្បញ្ញត្តិមិនស្មើគ្នា → | សិទ្ធិផ្តាច់មុខនិងគុណសម្បត្តិនៃតំណែងដែលកំពុងកាន់<br>ការប្រព្រឹត្តអនុគ្រោះផ្សេងទៀត |
| ៣ | អភិបាលកិច្ចសាជីវកម្ម → | គ្មានការបែងចែករវាងមុខងារនីតិបញ្ញត្តិ និងមុខងារពាណិជ្ជកម្ម<br>ការលើកលែងពីវិធានកាន់កាប់និងវិធានក្ស័យធន |

## ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច និងសេវាកម្មដឹកជញ្ជូនកញ្ចប់តូចៗ

ជំងឺរាតត្បាតកូវីដ១៩ កំពុងតែបង្អាក់ខ្សែសង្វាក់ការផ្គត់ផ្គង់ជាសកលនៅក្នុងរូបភាពមួយដែលមិនធ្លាប់មានពីមុនមក ហើយនឹងមានផលប៉ះពាល់ដល់ផ្នែកសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ដោយមានការធ្លាក់ចុះផលិតផលក្នុងស្រុកសរុប (GDP) នៅក្នុងប្រទេសជាសមាជិកអាស៊ានភាគច្រើន រួមបញ្ចូលទាំងប្រទេសកម្ពុជាផងដែរ។ ទោះជាយ៉ាងនេះក្តី ជាលទ្ធផលនៃការរីករាល ដាលជំងឺកូវីដ ១៩ ការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចមានការកើនឡើងយ៉ាងគំហុក។ ជំងឺរាតត្បាតកូវីដ ១៩ នាំឱ្យមានការផ្លាស់ប្តូររយៈពេលវែង ដោយការបង្កើនល្បឿននៃការផ្លាស់ប្តូរទៅរកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចវិញ។ អាជីវកម្មដែលមានហាងជារូបវន្តជាច្រើន មានការវិវត្តដោយការផ្តល់ជូនសេវាកម្មហួសពីការលក់រាយ រាប់បញ្ចូលទាំងការដឹកជញ្ជូនដល់គោលដៅចុងក្រោយ។ នៅក្នុងប្រទេសកម្ពុជា វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចមានការរីកចម្រើនយ៉ាងឆាប់រហ័ស ហើយមានសក្តានុពលយ៉ាងខ្លាំងសម្រាប់ការអភិវឌ្ឍបន្តទៅមុខទៀត ម្យ៉ាងវិញទៀតកត្តាទាំងនេះអាចចូលរួមចំណែកទៅដល់ការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ចរបស់ប្រទេស។ ប្រាក់ចំណូលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចត្រូវបានគេប៉ាន់ស្មានថានឹងឈានដល់ ២២២ លានដុល្លារក្នុងឆ្នាំ ២០២១ និង ៣១៣ លានដុល្លារនៅឆ្នាំ ២០២៥ ជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំ ៩% រវាងឆ្នាំ ២០២១ និង ២០២៥។ រដ្ឋាភិបាលបានដាក់ចេញនូវច្បាប់ និងគំនិតផ្តួចផ្តើមជាច្រើនដើម្បីគាំទ្រដល់កំណើនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលជួយដល់ការផ្លាស់ប្តូររបស់សហគ្រាសធុនតូច និងមធ្យម ឱ្យក្លាយជាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចបាន។ បើទោះជាមានគំនិតផ្តួចផ្តើមនេះ នៅតែមានឧបសគ្គដែលប៉ះពាល់ដល់អត្រាលូតលាស់ខាងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ដូចជាតម្លៃខ្ពស់

សម្រាប់ការដឹកជញ្ជូនដល់គោលដៅចុងក្រោយ។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធក៏ជាគន្លឹះក្នុងការតភ្ជាប់តំបន់ទីក្រុង និងជនបទ ជំរុញការដឹកជញ្ជូនតាមព្រំដែន។

## សហគ្រាស SOE និងវិស័យសេវាកម្មដឹកជញ្ជូនកញ្ចប់តូច

នៅប្រទេសកម្ពុជា សហគ្រាសកាន់កាប់ដោយរដ្ឋ(SOEs) (ហៅថា "សហគ្រាសសាធារណៈ") គឺជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ មានបេសកកម្មជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់ប្រទេស។ ដោយផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការទៅជាសេដ្ឋកិច្ចទីផ្សារ រដ្ឋាភិបាលបានធ្វើឯកជនភាវូបនីយកម្ម សហគ្រាសកាន់កាប់ដោយរដ្ឋ (SOEs) ជាច្រើនក្នុងរយៈពេលជាច្រើនឆ្នាំ។ ប្រទេសនេះ មានសហគ្រាសកាន់កាប់ដោយរដ្ឋ (SOEs) ចំនួន ១៨៧ ដែលគ្រប់គ្រងទាំងស្រុងដោយរដ្ឋនៅឆ្នាំ១៩៨៩។ ត្រឹមចុងឆ្នាំ២០០០ មាន ១៦០ ត្រូវបានធ្វើឯកជនភាវូបនីយកម្មទាំងស្រុង ឬដោយផ្នែក។គិតត្រឹមខែកុម្ភៈឆ្នាំ ២០២០ សហគ្រាស SOE ចំនួន ១៣ ក្នុងនោះរួមមានក្រុមហ៊ុនបណ្តាក់ទុនរួមគ្នាចំនួន ២ នៅក្នុងប្រទេសកម្ពុជា។

ប្រៃសណីយ៍កម្ពុជា ជាសហគ្រាសសាធារណៈមួយដែលកាន់កាប់ដោយរដ្ឋទាំងស្រុង បេសកកម្មរបស់វាគឺពង្រឹងសេដ្ឋកិច្ចជាតិខណៈពេលដែលការផ្លាស់ប្តូររចនាសម្ព័ន្ធហិរញ្ញវត្ថុ និងរដ្ឋបាលរបស់ខ្លួន ដើម្បីធ្វើទំនើបកម្ម សេវាប្រៃសណីយ៍ បង្កើនបទដ្ឋាន និងភាពសមរម្យនៃតម្លៃ ប្រៃសណីយ៍កម្ពុជាផ្តល់ជូនសេវាកម្មចែកចាយកញ្ចប់តូចទាំងក្នុងស្រុកនិងក្រៅស្រុក។

ការរីកចម្រើនយ៉ាងឆាប់រហ័សរបស់វិស័យនេះបានទាក់ទាញក្រុមហ៊ុនដឹកជញ្ជូនជាភាគីទីបីមួយចំនួនក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ៖នៅក្នុងខែកុម្ភៈ ឆ្នាំ២០២០ មានក្រុមហ៊ុនប្រតិបត្តិការដែលទទួលបានអាជ្ញាប័ណ្ណចំនួន ៤៣ ក្រុមហ៊ុនដែលកំពុងមាន សកម្មភាពក្នុងប្រទេសកម្ពុជា។ មួយចំនួន នៃក្រុមហ៊ុនទាំងនេះ ជាក្រុមហ៊ុននៅក្នុងស្រុកដែលទើបនិងបង្កើតឡើងថ្មីៗ ផ្សេងទៀត ផ្តោតទៅលើផ្នែកទីផ្សារដឹកជញ្ជូនដល់គោលដៅចុងក្រោយ និងការចែកចាយនៅក្នុងទីក្រុងភ្នំពេញ។ លើសពីនេះទៅទៀតក្រុមហ៊ុនប្រតិបត្តិការដែលមិនមានអាជ្ញាប័ណ្ណជាច្រើនបានរ៉ាប់រងទៅលើការចែកចាយទំនិញមួយផ្នែកធំ។

បើទោះជាមានបណ្តាញដ៏ទូលំទូលាយក៏ដោយ ប៉ុន្តែប្រៃសណីយ៍កម្ពុជាហាក់ដូចជាមិនមានវត្តមាន នៅក្នុងទីផ្សារក្នុងស្រុក នោះទេ ហើយវាក៏មិនត្រូវបានគេចាត់ទុកថា កំពុងតែប្រកួតប្រជែងយ៉ាងប្រកៀកប្រកិតជាមួយនឹងដៃគូប្រកួតប្រជែងនៅក្នុងសកលលោក និងនៅក្នុងផ្នែកទីផ្សារសេវាចែកចាយកញ្ចប់តូចអន្តរជាតិនោះដែរ។

**អនុសាសន៍សំខាន់ៗ**

1. កំណត់ឱ្យបានច្បាស់ និងបង្ហាញជាសាធារណៈនូវវត្ថុបំណងនៃគោលនយោបាយសាធារណៈរបស់ប្រៃសណីយ៍កម្ពុជា។ ធានាថាប្រៃសណីយ៍កម្ពុជាទទួលបានសំណងគ្រប់គ្រាន់សម្រាប់វត្ថុបំណងនៃគោលនយោបាយសាធារណៈរបស់ខ្លួន ហើយប្រាក់ចំណូល និងចំណាយទាក់ទងនឹងសកម្មភាពទាំងនេះត្រូវបានបែងចែកយ៉ាងច្បាស់លាស់នៅក្នុងគណនីរបស់ខ្លួន។
2. អនុម័តច្បាប់ស្តីពីការប្រកួតប្រជែងដើម្បីទទួលបានអត្ថប្រយោជន៍ពេញលេញពីទីលានប្រកួតស្មើភាព ហើយមិនលើកលែង សហគ្រាសកាន់កាប់ដោយរដ្ឋ (SOEs) ពីវិសាលភាពនៃច្បាប់ស្តីពីការប្រកួតប្រជែងនេះឡើយ។ ការរួមបញ្ចូលយ៉ាងច្បាស់លាស់នូវ សហគ្រាសកាន់កាប់ដោយរដ្ឋ (SOEs) នៅពេលកំណត់វិសាលភាពនៃភាពអាចអនុវត្តបានអាចបង្កើនភាពប្រាកដប្រជាផ្នែក ច្បាប់ នៅក្នុងន័យនេះ។
3. ធានានូវឯករាជ្យភាពរបស់អាជ្ញាធរប្រកួតប្រជែងដើម្បីចៀសវាងការប៉ុនប៉ងរបស់ក្រសួងនានា ឬអាជ្ញាធររដ្ឋាភិបាលផ្សេងទៀតដើម្បី មានឥទ្ធិពលដល់ការសម្រេចចិត្តរបស់អាជ្ញាធរប្រកួតប្រជែងក្នុងការស៊ើបអង្កេតការប្រព្រឹត្តរបស់ សហគ្រាសកាន់កាប់ដោយរដ្ឋ (SOEs)។
4. អនុវត្តលក្ខខណ្ឌតម្រូវនៃការផ្តល់អាជ្ញាបណ្ណ និងកម្រៃសេវាដូចគ្នាចំពោះប្រៃសណីយ៍កម្ពុជា និងអ្នកផ្តល់សេវាដឹកជញ្ជូនទំនិញកញ្ចប់តូចដែលកាន់កាប់ដោយឯកជន។ ម្យ៉ាងវិញទៀត សូមពិចារណាសម្រួលនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណឱ្យមានភាពសាមញ្ញ និងកាត់បន្ថយថ្លៃដើមសម្រាប់អ្នកផ្តល់សេវាដែលកាន់កាប់ដោយឯកជន។
5. ចៀសវាងការលើកលែងពន្ធណាមួយលើសកម្មភាពពាណិជ្ជកម្មរបស់ប្រៃសណីយ៍កម្ពុជា។
6. ធ្វើវិសោធនកម្មអនុក្រឹត្យលេខ ៤១ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ (បំពេញបន្ថែមដោយអនុក្រឹត្យលេខ ៧១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១) ដែលបង្ហាញយ៉ាងច្បាស់ថាប្រាក់កម្ចី និងបំណុលរបស់ សហគ្រាសកាន់កាប់ដោយរដ្ឋ (SOEs) មិនត្រូវបានធានាដោយរដ្ឋឡើយ។

**ប្រភព៖** Statista; ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ; ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## ជំរុញការប្រកួតប្រជែងក្នុងតំបន់អាស៊ាន

ដោយទទួលបានមូលនិធិពីកម្មវិធីកំណែទម្រង់សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Reform Programme) ក្រោមការិយាល័យអភិវឌ្ឍន៍ ខុមិនវែលនិងការបរទេស នៃចក្រភពអង់គ្លេស (UK Foreign, Commonwealth & Development Office) (រដ្ឋាភិបាលចក្រភពអង់គ្លេស)គម្រោងជំរុញការប្រកួតប្រជែងក្នុង តំបន់អាស៊ានគឺជាគម្រោងមួយដែលមានគោលបំណងធ្វើការវាយ តម្លៃឧបសគ្គខាងផ្លូវច្បាប់ទៅលើការប្រកួតប្រជែង ក្នុងវិស័យភ័ស្តុភារក្នុងប្រទេសជាសមាជិកអាស៊ានទាំង ១០ ដោយការកំណត់បទប្បញ្ញត្តិនានាដែល រាំងស្ទះដល់ប្រសិទ្ធភាពនៃដំណើរការក្នុងទីផ្សារ និងបង្កើតឱ្យមានទីប្រកួតប្រជែងដែលមិនស្មើភាពគ្នាសម្រាប់អាជីវកម្ម។ គម្រោងនេះដំណើរការសមាសធាតុពីរស្របគ្នា៖ ការពិនិត្យឡើងវិញលើការវាយតម្លៃការប្រកួតប្រជែង ក្នុងអនុវិស័យភ័ស្តុភារជាក់លាក់ និងការពិនិត្យមើលអព្យាក្រឹត្យភាពនៃការប្រកួតប្រជែងរបស់សេវាកម្មដឹកជញ្ជូនកញ្ចប់តូច។

របាយការណ៍នេះនិងឯកសារអម "ការពិនិត្យឡើងវិញលើការវាយតម្លៃប្រកួតប្រជែងរបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍសេដ្ឋកិច្ច (OECD)៖ វិស័យដឹកជញ្ជូននៅកម្ពុជា" គឺជាការរួមចំណែកដល់ការអនុវត្តផែនការសកម្មភាពការប្រកួតប្រជែងរបស់អាស៊ាន។




ចូលមើលការពិនិត្យឡើងវិញនិងព័ត៌មានច្រើនទៀតក្នុងគម្រោងនេះនៅគេហទំព័រ **oe.cd/comp-asean**

OECD
BETTER POLICIES FOR BETTER LIVES

UK Government

ASSOCIATION OF SOUTHEAST ASIAN NATIONS